# ២២.ដើមចេកជ្វា និងដើមបាយម៉ាត

ចាស់បុរាណខ្មែរយើង ច្រើនជឿហើយហាមប្រាមកូនចៅ មិនឲ្យដាំដើមចេកជ្វានៅជិតសំយាបផ្ទះ ព្រោះគេយល់ថា វាដាក់ម្ចាស់ផ្ទះ ។ បានជាមានជំនឿយ៉ាងនេះ ដោយមានរឿងដំណាលដូចតទៅ ៖
ជាយូរអង្វែងណាស់មកហើយ មានគ្រួសារមួយ ជាអ្នកទីទ័លក្រ ប្រកបរបររកស៊ីជាកសិករ ។ ក្នុងពេលមួយដែលជារដូវរាំងឫស ឥតមានភ្លៀងធ្វើស្រែ បុរសប្តីក៏លាប្រពន្ធ ទៅរកស៊ីឈ្នួលគេ

នៅស្រុកឆ្ងាយ ។ ក្រោយដែលបុរសនេះចេញផុតទៅ ស្រុកកើតជំងឺអហិវាតរោគ រាតត្បាត ពាសពេញបណ្តាលឲ្យអ្នកភូមិទាំងមូល ភ័យជ្រួលច្របល់យ៉ាងសម្បើម ។ មុនដំបូង, ជំងឺនោះបណ្តាលឡើងអំពីសត្វតូចតាច លុះយូរបន្តិចទៅ ក៏រាលដាលរហូតដល់សត្វធំៗ រហូតដល់ជីវិតមនុស្សក្នុងភូមិផង គ្មាននរណាអាចជួយនរណាបានឡើយ ។ ផ្ទះនីមួយ ៗ ស្ងាត់ឈឹង ពេលយប់គេឮតែសំឡេងឆ្កែលូ និងពន្លឺភ្លើងប្រទីបផ្លុង ៗ ត្រង់នេះមួយ ត្រង់នោះមួយ គួរឲ្យព្រឺក្បាលពន់ពេក ។

នៅភូមិខ្លះ ដែលរោគនេះមិនទាន់រាលដាលទៅដល់ អ្នកនិគមជនបទទាំងនោះ ក៏ពុំហ៊ានដើរស្វែងរក ប្រកបកិច្ចការរហេតរហូត ដូចប្រក្រតីឡើយ ។ មនុស្សទាំងនោះ មានកិរិយាស្ងប់ស្ងៀម

មានទឹកមុខក្រៀមក្រំ ស្រពាប់ស្រពោនជានិច្ច និយាយរកគ្នាទៅវិញទៅមកដោយខ្សឹបខ្សៀវ មិនហ៊ាននិយាយគ្នាកោកកាក ឬ នឹកឈ្មោះទីកន្លែង ដែលកើតជំងឺចង្រៃទាំងនោះផងទេ ។

មានថ្ងៃមួយ នៅពេលដែលជំងឺកំពុងតែបង្កើនឥទ្ធិពលយ៉ាងខ្លាំង ស្រាប់តែមានទាយកម្នាក់មកនិមន្តព្រះសង្ឃ ៤ អង្គទៅចម្រើនព្រះបរិត្តនៅផ្ទះរបស់ខ្លួន ។ លុះដល់កំណត់ ទាយកនោះក៏មកទទួល

ព្រះថេរៈចៅអាវាស ព្រមទាំងភិក្ខុ ៣ រូបទៀត និមន្តទៅដល់ផ្ទះឧបាសកនោះ ឃើញមានភ្ញៀវយ៉ាងច្រើន ។ គេក៏និមន្តព្រះសង្ឃទាំង ៤ អង្គឡើងលើផ្ទះ គង់លើអាសនៈ យ៉ាងសមគួរ ហើយប្រគេនភេសជ្ជៈ តែស្លាបារីតាមទំនៀម ។ បន្ទាប់មក គេនាំគ្នានមស្ការព្រះរតនត្រ័យ រួចអារាធនាព្រះសង្ឃចម្រើនព្រះបរិត្ត, ប៉ុន្តែគេទូលលោកថា ៖ " សូមលោកម្ចាស់ កុំសូត្រ " ធមិករណីយ៍ " សូមនិមន្តសូត្ររំលងទៅ " វិរូបក្ខេ " តែម្តងទៅ ដើម្បីកុំឲ្យយូរពេល ។ ព្រះសង្ឃចាប់ផ្តើមចម្រើនព្រះបរិត្ត តាំងអំពីដើមរៀងទៅ, លុះដល់ " ធមិករណីយ៍ " លោកក៏រំលងចោល ទៅសូត្រ " វិរូបក្ខេ " តាមពាក្យទាយកបវារណាសុំតែម្តង ។ ក្នុងពេលនោះ, លោកសង្កេតឃើញទាយកទាយិកា សប្បាយរីករាយសើចញញឹមញញែមក្របួចមាត់ក្របួចក គ្រប់ ៗ គ្នា ។ ព្រះថេរៈដើមអាសនៈនឹកឆ្ងល់ថា ៖ គេសុំកុំឲ្យសូត្រ " ធមិករណីយ៍ " សុំឲ្យផ្លោះទៅសូត្រ " វិរូបក្ខេ " តែម្តង, ឥឡូវសូត្រវិរូបក្ខេទៅ ស្រាប់តែនាំគ្នាសប្បាយបែបដូចជាប្លែក ។ ព្រះថេរៈនឹកអៀនក្នុងព្រះទ័យណាស់ ខ្លាចក្រែងគេរិះគន់ថាលោកសូត្រខុស ទើបត្រឡប់មកចាប់សូត្រធមិករណីយ៍ វិញ ។ លោកទើបតែនឹងចាប់សូត្របាន ៣-៤ ព្រះឱស្ឋ, ស្រាប់តែទាយកទាយិកានាំគ្នាដកខ្លួនថយបន្តិចម្តង ៗ រហូតដល់អស់រលីង ស្ងាត់សូន្យឈឹង ។ ភ្លើងក៏រលត់ភ្លឹប ផ្ទះដែលព្រះសង្ឃឡើងទៅនោះ ត្រឡប់ទៅជាគុម្ពឫស្សីយ៉ាងញាតស្បាត បារី-តែស្លាទៅជាដុំ

ផ្សេង ដីខ្សាច់ និងកំណាត់ឈើអស់ ។ ទើបព្រះសង្ឃភ្ញាក់ ថាបិសាចក្លែងខ្លួនធ្វើមនុស្ស ។ ទម្រាំតែភិក្ខុផងគ្នានៅឯវត្តដឹងថា ៖ លោកគ្រូជាប់នៅចុងឫស្សី លោកគ្រូនិងព្រះសង្ឃ ៣ អង្គទៀតត្រូវអត់ចង្ហាន់ ២-៣ ថ្ងៃ ។ ដោយហេតុហ្នឹងហើយ ទើបចាស់បុរាណលោកថា ៖ " ធមិករណីយ៍ " នេះធ្វើឲ្យខ្មោចខ្លាចណាស់ ។ ឯធមិវិរូបក្ខេ ធ្វើឲ្យខ្មោចសប្បាយទៅវិញ ។ កាលណាស្រុកមិនសូវស្រួល ដោយមានកើតជំងឺដង្កាត់ផ្សេង ៗ មានអាសន្នរោគ,អុតជាដើមនោះ គេតែងនិមន្តព្រះសង្ឃ ចម្រើនព្រះបរិត្ត ហើយសុំឲ្យលោកសូត្រធមិករណីយ៍នេះ ឲ្យបាន ៧-៨ ចប់ ហើយហាមផ្តាច់មិនឲ្យព្រះសង្ឃ សូត្រធមិវិរូបក្ខេឡើយ ដោយមានជំនឿតាមរឿងដូចបានរៀបរាប់មកខាងលើនេះ ។ ម្យ៉ាងទៀតបុរាណមានជំនឿថា ៖ បើយើងដើរទៅណាមកណាយប់ ហើយមានព្រឺរោម ព្រឺស្រែកត្រូវឲ្យសូត្រធមិករណីយ៍នេះដែរ ដោយសម្អាងថាខ្មោចមិនលង ។

និយាយពីបុរសដែលទៅរកស៊ីស្រុកឆ្ងាយនោះ ក្រោយដែលបានទៅរកស៊ីមានលុយកាក់ល្មមត្រឡប់មកលំនៅម្តងហើយ ក៏វិលត្រឡប់មកស្រុកកំណើតវិញ ។ មកដល់កណ្តាលផ្លូវគេប្រាប់ថា ៖

អ្នកឯងទៅមិនទាន់បានទេ, ព្រោះភូមិអ្នកឯងនោះ កើតជំងឺអាសន្នរោគច្រើនណាស់ មនុស្សអ្នកភូមិស្លាប់គ្មាននរណាកប់នរណាទេ ឯប្រពន្ធកូនរបស់អ្នកឯង ក៏ប្រហែលជាស្លាប់ទៅហើយ ឬ យ៉ាងណា ក៏មិនដឹងព្រោះអ្នកភូមិដទៃ ឥតមាននរណាម្នាក់ហ៊ានចូលទៅទេ ។ បុរសនោះដោយសេចក្តីនឹកប្រពន្ធ-កូនខ្លាំងពេក ក៏ចេះតែចចេសចូលទៅ គាត់ខំធ្វើដំណើរទៅទាំងយប់ ហើយទាំងសស្លើតសស្លក់ផង ។ លុះទៅជិតដល់លំនៅខ្លួន មើលទៅឃើញភ្លើងផ្លុង ៗ គ្រប់ៗផ្ទះ ដូចប្រក្រតី គាត់ត្រេកអរណាស់ ហើយនឹកខឹងនឹងអ្នកស្រុកដែលប្រាប់ពីកណ្តាលផ្លូវថា ៖ គេនិយាយកុហកខ្លួន ។ ប៉ុន្តែនៅតាមផ្លូវទៅផ្ទះគាត់ គាត់មានសេចក្តីសង្ស័យដែរ ចំពោះសភាពស្ងប់ស្ងាត់ប្លែកពីធម្មតា តែគាត់សន្និដ្ឋានថា ប្រហែលជាអ្នកស្រុកមិនស្រួលមែនទើបស្ងាត់យ៉ាងនេះ ។ លុះទៅដល់ទ្វាររបងផ្ទះក៏ស្រែកហៅប្រពន្ធ, ពេលនោះគាត់ឃើញស្រីម្នាក់ ដែលគាត់បានស្គាល់ច្បាស់ ថាជាប្រពន្ធរបស់គាត់ រត់មកទទួលរាក់ទាក់ នឹងគាត់ដូចដូចធម្មតា គ្មានអ្វីគួរឲ្យសង្ស័យសោះ ។

នាងនោះខំប្រញិបប្រញាប់ ទៅបង្កាត់ភ្លើងដាំបាយឲ្យប្តីបរិភោគ, ប៉ុន្តែនាងហាមប្តីមិនឲ្យចូលទៅក្នុងបន្ទប់ដេកនាងទេ ឲ្យគាត់សម្រាកនៅខាងក្រៅសិនហើយ ។

ប្តីនឹកឆ្ងល់នឹងឥរិយាបថដ៏ចម្លែករបស់ភរិយាណាស់ ដោយគាត់សង្កេតឃើញភ្នែកនាងធំៗ លៀនៗ បែបក្រហម ហើយក្រឡឹបក្រឡាប់ខុសពីធម្មតា ថែមទាំងធុំក្លិនគំរង់សាកសព បក់ចេញពីបន្ទប់ដេក ម្តងៗ ផងគាត់ក៏ចង់ដឹងថាមានអ្វីនៅក្នុងបន្ទប់ដេកនោះ បានជានាងឃាត់មិនឲ្យចូល ? គិតសព្វគ្រប់ទៅ ក៏ចេះតែអង្គុយសង្កេតកិរិយារបស់ប្រពន្ធ, បន្តិចមក ឃើញលៀនអណ្តាតយ៉ាងវែងកេរយកវែកដែលរបូតពីដៃធ្លាក់ទៅដីមកវិញ ។ ប្តីដែលចេះតែសម្ងឹងអាកប្បកិរិយាប្រពន្ធ កាលបើឃើញដូច្នោះ ដឹងថាមិនមែនជាប្រពន្ធខ្លួនពិតប្រាកដទេ គឺច្បាស់ជាពួកបិសាចក្លែងភេទ ហើយទើបនឹកឃើញដល់រឿងដែលគេនិយាយប្រាប់ពីកណ្តាលផ្លូវថា មានពួកបិសាចធ្វើបាបលោកសង្ឃ ដូចរៀបរាប់មកហើយ នោះភ្លាម, ក៏លបចូលទៅវែកមុងក្នុងបន្ទប់របស់ប្រពន្ធខ្លួនមើល ឃើញខ្មោចប្រពន្ធកូនខ្លួនស្លាប់ស្អុយរលួយដង្កូវរុកជ្រិច ។

គាត់ថយចេញមកវិញ ហើយគិតរកមធ្យោបាយដើម្បីដោះខ្លួនអំពីកណ្តាប់ដៃមេបិសាចនេះ ទើបគាត់និយាយទៅកាន់នាងនោះថា " ឯងដាំបាយឲ្យឆ្អិនឆាប់ទៅវ៉ី គ្នាអស់កម្លាំងណាស់

គ្នាទៅនោមនៅចុងរានក្រៅផ្ទះឯណោះមួយភ្លែត ។ ថាហើយគាត់ក៏ទៅ ចោះក្អមទឹកមួយដែលនៅក្បែរនោះ បង្ហូរទឹកទៅដី ឮដូចមនុស្សនោមមែន ។ ចោះរួចគាត់លបចុះ រត់បាតជើងសព្រាតតម្រង់ទៅរកអារាមមួយ ដែលមានលោកគ្រូមួយអង្គ ចេះមន្តអាគមគាថា ពូកែខាងការពារខ្មោចបិសាច និងអាបធ្មប់ ។

ចំណែកនាងបិសាច ឮស្វរប្តីនោមយូរពេក នឹកឆ្ងល់ ក៏តាមទៅមើល, មិនឃើញប្តី ក៏មឹតរត់តាមក្រោយយ៉ាងលឿន ដល់ពាក់កណ្តាលផ្លូវឃើញប្តី ។ ចំណែកឯប្តី រត់មិនទាន់បានប៉ុន្មាន

ងាកក្រោយឃើញខ្មោចដេញតាម ដឹងខ្លួនថាមើលទៅស្ទុះមិនរួចអំពីកណ្តាប់ដៃបិសាច ក៏រត់ឡើងដើមបាយម៉ាត ១ ដើមដែលនៅក្បែរនោះ ។ នាងបិសាចមិនហ៊ានទៅជិតដើមនោះសោះ ចេះតែដើរក្រឡឹង ៗ ក្បែរ ៗ ហើយស្រែកហៅប្តីឲ្យចុះមក ។

បុរសនោះដឹងថានាងបិសាចនេះ ពិតជាខ្លាចដើមបាយម៉ាតនេះហើយ បានជាមិនហ៊ានមកជិតអញសោះ ក៏កាច់មែកបាយម៉ាត ១ មែក លីដើរសំដៅទៅវត្តទៅ

ឯនាងបិសាចពិតមែនតែមិនហ៊ានទៅជិតបុរសជាប្តី ដោយខ្លាចដើមបាយម៉ាតមែន តែនាងនៅតែដើរតាមក្រោយរហូត ។ បុរសទៅដល់វត្តស្ទុះចូលទៅកណ្តាលជំនុំព្រះសង្ឃ ដែលកំពុងធ្វើឧបោសថកម្មនៅក្នុងព្រះវិហារ ហើយពិតពុទ្ធដីកាព្រះសង្ឃតាមដំណើរ ។ ពេលនោះលោកគ្រូដែលពូកែខាងមន្តអាគមគាថា ក៏នាំបុរសទៅនៅក្នុងកុដិរបស់លោក ហើយសូត្រអាគមគាថា ព័ទ្ធសីមាយ៉ាងស្វាហាប់ ។ ឯនាងបិសាចក៏មិនទៅណាឆ្ងាយ អំពីកុដិព្រះសង្ឃនោះទេ ។ ពិតមែន តែនាងចូលទៅក្នុងកុដិលោក តាមប្តីរបស់នាងមិនបាន ដោយរបាំងនៃមន្តអាគមគាថា, ប៉ុន្តែ នាងចេះតែក្រវែលរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីចូលទៅតាមប្តី ។

ទៅក្បែរកុដិព្រះថេរៈអង្គនោះ មានដើមចេកជ្វា ១ ដើម ដែលមានធាងដុះចូលទៅត្រង់បង្អួចកុដិ ។ ទោះបីមន្តអាគមរបស់លោកដ៏ពូកែយ៉ាងណា ក៏មិនអាចទប់ឈ្នះនឹងដើមចេកជ្វានោះដែរ ។

លោកព័ទ្ធសីមាបានតែត្រង់កន្លែងណា ដែលធាងចេកជ្វា មិនទៅប៉ះនឹងសំយាបកុដិប៉ុណ្ណោះ ចំពោះ ១ ភាគតូចនៃកុដិរបស់លោក ដែលធាងចេកជ្វាទៅប៉ះនោះ នៅចន្លោះជាឱកាសដ៏ប្រសើរដល់នាងបិសាច, នាងបិសាចក៏ឡើងតាមដើមចេកជ្វា ហើយស្ទូតាមធាងចេកនោះ ឆ្លងចូលទៅក្នុងកុដិរបស់លោក កាច់កប្តីរបស់ខ្លួនសម្លាប់ក្នុងពេលនោះទៅ ។

ព្រោះហេតុមានរឿងនិទានមកនេះហើយ ទើបបុរាណខ្មែរយើងនិយមជំនឿនេះ ហាមប្រាមកូនចៅ មិនឲ្យដាំដើមចេកជ្វានៅជាប់នឹងសំយាបផ្ទះ គេថាវាដាក់ខ្លួន ។

ឯដើមបាយម៉ាតក៏បានជាឱសថសម្រាប់ការពារមួយមុខយ៉ាងពូកែ ចំពោះខ្មោចព្រាយបិសាចនិងអាបធ្មប់ជាប់រហូតមកដល់សព្វថ្ងៃនេះ ។